Australian Government

GLOBAL INITIATIVE AGAINST TRANSNATIONAL ORGANIZED CRIME

គោលការណ៍ណែនាំស្តីពីឱកាសទទួលបានជំនួយថវិកា

MEKONG NETWORK TO COUNTER TRANSNATIONAL CRIME (MNET-CTC)

GLOBAL INITIATIVE AGAINST TRANSNATIONAL ORGANIZED CRIME (GI-TOC)

2026

ចំនួនទឹកប្រាក់ជំនួយ និងរយៈពេលនៃជំនួយ

រយៈពេលអតិបរមានៃការផ្តល់ជំនួយតតសំណង គឺមួយឆ្នាំ(១២ ខែ)។
អ្នកដាក់ពាក្យស្នើសុំជំនួយក៏អាចស្នើគម្រោង
ឬកម្មវិធីដែលមានរយៈពេលអនុវត្តខ្លីជាងនេះផងដែរ។

រយៈពេលអនុវត្តគម្រោងដែលទទួលបានជំនួយ នឹងចាប់ផ្តើមពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៧
ដល់ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៨។

- ជាទូទៅ គេរំពឹងថាជំនួយភាគច្រើននឹងមានចំនួនចន្លោះពី ៣០,០០០ ដុល្លារអូស្ត្រាលី ដល់
  ៦៥,០០០ ដុល្លារអូស្ត្រាលី ដោយផ្អែកលើវិសាលភាពនៃសកម្មភាពគម្រោង
  កម្រិតភាពស្មុគស្មាញ
  និងថាតើគម្រោងសហការនេះត្រូវបានអនុវត្តដោយក្រុមចម្រុះនៃអង្គការដៃគូឬយ៉ាងណា។
  កម្រិតថវិកាអតិបរមាដែលអាចស្នើសុំបាន គួរតែគិតគូរពីរយៈពេល
  និងភាពស្មុគស្មាញនៃសកម្មភាពដែលបានស្នើឡើង។
- កម្មវិធី MNET-CTC
  នឹងឧតុំបែងចែកថវិកាតាមសមាមាត្ររវាងប្រទេសទាំងបួនក្នុងតំបន់មេគង្គ រួមមាន
  កម្ពុជា ឡាវ ថៃ និងវៀតណាម។ កម្មវិធី MNET-CTC
  ក៏អាចបែងចែកថវិកាសម្រាប់កម្មវិធីដែលផ្តោតលើប្រទេសមីយ៉ាន់ម៉ាផងដែរ។

ប្រសិនបើអ្នកដាក់ពាក្យមានប្រភពថវិកាផ្សេងទៀតសម្រាប់ចូលរួមគាំទ្រគម្រោងរបស់ខ្លួន GI-TOC
លើកទឹកចិត្តឱ្យបញ្ជាក់អំពីសមាមាត្រថវិកាដែលទទួលបានពីប្រភពផ្សេងទៀតទាំងនោះនៅក្នុងសំណើថវិកា។ មិនមានការកំណត់ចំនួនថវិកាអប្បបរមា
ឬអតិបរមាដែលត្រូវទទួលបានពីប្រភពផ្សេងទៀត
ដើម្បីមានសិទ្ធិដាក់ពាក្យស្នើសុំជំនួយនេះឡើយ។

ជំនួយថវិកាគឺសម្រាប់កម្មវិធីដែលមានរយៈពេលកំណត់
និងមិនមែនជាកម្មវិធីបន្តរយៈពេលវែងនោះទេ។ ដូច្នេះ
ការផ្តល់ជំនួយនឹងបញ្ចប់នៅពេលផុតកំណត់រយៈពេលនៃការផ្តល់ជំនួយ។

លក្ខខណ្ឌសិទ្ធិទទួលបានជំនួយ

GI-TOC មិនអាចពិចារណាលើពាក្យស្នើសុំពីរដ្ឋដែនដី ឬស្ថាប័ន
និងអង្គភាពរបស់រដ្ឋាភិបាលបានឡើយ។ ដើម្បីមានសិទ្ធិដាក់ពាក្យស្នើសុំ អង្គការ និង/ឬ បុគ្គល
ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ជាអង្គភាពនីតិបុគ្គល ឬមានឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវច្បាប់
  និងមានសមត្ថភាពក្នុងការចុះកិច្ចព្រមព្រៀង
  ឬកិច្ចសន្យាដែលមានអានុភាពតាមផ្លូវច្បាប់។
- បង្ហាញពីបទពិសោធន៍កន្លងមកក្នុងការអនុវត្តសកម្មភាពដែលដោះស្រាយដោយផ្ទាល់នូវបញ្ហាពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំងក្នុងតំបន់មេគង្គ

លើប្រធានបទដូចជាគ្រឿងញៀន បទល្មើសហិរញ្ញវត្ថុ ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និង/ឬ កត្តាជំរុញ និងកត្តាអំណោយផលដែលមានឥទ្ធិពលឆ្លងកាត់វិស័យផ្សេងៗ ដែលពាក់ព័ន្ធនឹងសេដ្ឋកិច្ចខុសច្បាប់។
- អាចប្រើប្រាស់ភាសាអង់គ្លេស និង/ឬ ភាសាក្នុងតំបន់មេគង្គយ៉ាងហោចណាស់មួយ។

ការប្រើប្រាស់ថវិកាជំនួយថវិកា

សកម្មភាពគម្រោងដែលមានសិទ្ធិទទួលបានជំនួយ

ឱកាសទទួលបានជំនួយថវិកាសម្រាប់គម្រោងសហការក្រោមកម្មវិធីMNET-CTC
ផ្តោតលើសកម្មភាពគម្រោងដែលមានគោលបំណងបង្កើនភាពធន់នៅកម្រិតសហគមន៍។
សកម្មភាពដែលស្នើឡើងអាចមានទម្រង់ផ្សេងៗគ្នា
ប៉ុន្តែត្រូវរួមចំណែកដល់ការសម្រេចគោលបំណងពង្រឹងភាពធន់នៅកម្រិតសហគមន៍
និងត្រូវអនុវត្តតាមរយៈកិច្ចសហការ។

នេះមានន័យថា
សកម្មភាពទាំងនោះត្រូវផ្តល់លទ្ធផលដែលជួយពង្រឹងភាពធន់ក្នុងការប្រឈមនឹងគ្រឿងញៀនខុសច្បាប់ ឧក្រិដ្ឋកម្មហិរញ្ញវត្ថុ ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និង/ឬ កត្តាជំរុញ
និងកត្តាអំណោយផលដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មទាំងនេះ។
សកម្មភាពទាំងនេះត្រូវអនុវត្តដោយអង្គការចំនួនពីរ ឬបី ដែលធ្វើការរួមគ្នា។

- **តើវិធីសាស្ត្រពង្រឹងភាពធន់ក្នុងការប្រឈមនឹងឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំងមានន័យដូចម្តេច?**

គម្រោងដែលអនុវត្តវិធីសាស្ត្រពង្រឹងភាពធន់ក្នុងការប្រឈមនឹងឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំងត្រូវអាចបង្ហាញពីទំនាក់ទំនងយ៉ាងច្បាស់រវាងសកម្មភាពដែលបានស្នើឡើង
លទ្ធផលរំពឹងទុក និងនិន្នាការនៃឧក្រិដ្ឋកម្ម។

វិធីសាស្ត្រនេះអាចមានទម្រង់ និងរូបភាពផ្សេងៗគ្នា
ប៉ុន្តែសំណើគម្រោងត្រូវបង្ហាញពីការយល់ដឹងយ៉ាងច្បាស់អំពីសកម្មភាពឧក្រិដ្ឋកម្ម
ផលប៉ះពាល់អវិជ្ជមានដែលបង្កឡើងដោយឧក្រិដ្ឋកម្មទាំងនោះ និងមធ្យោបាយ
ឬកត្តាអន្តរាគមន៍ដែលអាចប្រើប្រាស់ ដើម្បីផ្លាស់ប្តូរប្រព័ន្ធដែលពាក់ព័ន្ធ។

វិធីសាស្ត្រនេះពិចារណាអំពីរបៀបដែលបុគ្គល ឬក្រុមនានារៀបចំ
និងប្រតិបត្តិសកម្មភាពឧក្រិដ្ឋកម្មធ្ងន់ធ្ងរ និងឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង
ព្រមទាំងកត្តាអំណោយផលដែលអនុញ្ញាតឱ្យតួអង្គទាំងនេះផ្លាស់ប្តូរ និងធ្វើពាណិជ្ជកម្មទំនិញ
និងសេវាកម្មខុសច្បាប់។

ភាពធន់ គឺជាសមត្ថភាពក្នុងការទប់ទល់ សម្របខ្លួន
និងរំខានដល់សកម្មភាពរបស់ឧក្រិដ្ឋកម្មរៀបចំជាក្រុម។
សន្ទស្សន៍ស្តីពីឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង(Organized Crime Index)ដែលធ្វើឡើងដោយអង្គការGI-TOC បានកំណត់វិមាត្រចំនួន១២នៃភាពធន់
ដែលជាមូលដ្ឋានគ្រឹះសម្រាប់ការឆ្លើយតបនៅក្នុងវិស័យនយោបាយ ច្បាប់ សេដ្ឋកិច្ច និងសង្គម។
នៅពេលរួមបញ្ចូលគ្នា វិមាត្រទាំងនេះមានសក្តានុពលក្នុងការផ្តល់នូវការឆ្លើយតបគ្រប់ជ្រុងជ្រោយ
និងប្រសិទ្ធភាពចំពោះឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង។

សកម្មភាពពង្រឹងភាពធន់
គឺជាសកម្មភាពទាំងឡាយណាដែលយកមូលដ្ឋានគ្រឹះទាំងនេះមកប្រើប្រាស់ជាកត្តាអន្តរាគមន៍
ដើម្បីផ្លាស់ប្តូរប្រព័ន្ធស្មុគស្មាញ និងទប់ស្កាត់សកម្មភាពឧក្រិដ្ឋកម្ម។

ដូច្នេះវិធីសាស្ត្រពង្រឹងភាពធន់ក្នុងការប្រឈមនឹងឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំងមានវិសាលភាពទូលំទូលាយជាងសកម្មភាព លទ្ធផលការងារ ឬសមិទ្ធផលជាក់លាក់ណាមួយ។
គោលគំនិតសំខាន់គឺ សកម្មភាពនានាត្រូវរួមចំណែកធ្វើឱ្យមានការផ្លាស់ប្តូរជាបន្តបន្ទាប់
និងបន្តិចម្តងៗនៅក្នុងប្រព័ន្ធ ដើម្បីធានាថាទំនិញ និងសេវាកម្មខុសច្បាប់មិនត្រូវបានផលិត
ដឹកជញ្ជូន រក្សាទុក ឬដោះដូរនោះទេ។

នៅពេលអនុវត្តប្រកបដោយជោគជ័យ
វិធីសាស្ត្រពង្រឹងភាពធន់នឹងផ្តល់លទ្ធផលដែលរួមចំណែកដល់វិមាត្រទាំង១២ នេះ
ដើម្បីឱ្យប្រព័ន្ធនយោបាយ ច្បាប់ សេដ្ឋកិច្ច និងសង្គមដំណើរការប្រកបដោយសង្គតិភាព
និងសហការគ្នាជាប្រព័ន្ធ។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់៖ www.ocindex.net។

- **តើវិធីសាស្ត្រផ្អែកលើសហគមន៍មានន័យដូចម្តេច?**

មិនមានវិធីសាស្ត្រផ្អែកលើសហគមន៍តែមួយដែលអាចអនុវត្តបានគ្រប់ករណីនោះទេ
ដោយសារការអន្តរាគមន៍នីមួយៗអាចមានលក្ខណៈខុសៗគ្នា ទៅតាមបរិបទដែលត្រូវដោះស្រាយ។

ទោះជាយ៉ាងណា ការងារនៅកម្រិតសហគមន៍ សំដៅលើការអន្តរាគមន៍ក្នុងទ្រង់ទ្រាយតូច
ដែលផ្តោតលើការដោះស្រាយលំហូរ និងការប្រមូលទុកទំនិញនៃទីផ្សារខុសច្បាប់
ការបង្កើនសមត្ថភាពស្រូបយកនិងទប់ទល់ផលប៉ះពាល់ពីរបៀតិ និងការលើកកម្ពស់ចំណេះដឹង
ឥរិយាបថ និងការអនុវត្តនៅក្នុងមូលដ្ឋាន។ ការអន្តរាគមន៍ក្នុងទ្រង់ទ្រាយតូចទាំងនេះ
អាចនាំឱ្យមានផលប៉ះពាល់កាន់តែទូលំទូលាយនៅថ្នាក់ជាតិ និងថ្នាក់តំបន់។

វិធីសាស្ត្រផ្អែកលើសហគមន៍ មិនមែនគ្រាន់តែសំដៅលើការធ្វើការងារ នៅក្នុង
សហគមន៍ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវធ្វើការងារ ជាមួយ សហគមន៍ផងដែរ
ដោយលើកទឹកចិត្តឱ្យសមាជិកសហគមន៍ចូលរួមយ៉ាងសកម្មក្នុងដំណើរការកសាងភាពធន់។

ការចូលរួមរបស់សហគមន៍ សំដៅលើការចូលរួមរបស់ប្រជាពលរដ្ឋក្នុងសកម្មភាពផ្សេងៗ
ដែលពួកគេមិនចាំបាច់ត្រូវមានជំនាញឯកទេស បទពិសោធន៍វិជ្ជាជីវៈ
ឬជាតួអង្គមានអំណាចក្នុងវិស័យណាមួយឡើយ។ ពួកគេចូលរួមសហការជាមួយអ្នកផ្តល់សេវា
សាលារៀន ក្រុមសាសនា និងសមាគមសហគមន៍នៅក្នុងមូលដ្ឋានរបស់ពួកគេ។

- **តើកិច្ចសហការមានន័យដូចម្តេច?**

ជាទូទៅ កិច្ចសហការសំដៅលើការដែលអង្គការពីរ ឬច្រើនធ្វើការរួមគ្នា
ដើម្បីសម្រេចគោលដៅរួមមួយ ដោយអង្គការនីមួយៗចូលរួមចែករំលែកចំណេះដឹង ជំនាញ
និងសមត្ថភាពរៀងៗខ្លួន។

កិច្ចសហការតម្រូវឱ្យមានការជឿទុកចិត្តគ្នាទៅវិញទៅមក
និងការជ្រាស្រ័យទាក់ទងគ្នាដោយបើកចំហ។ វាមានលក្ខណៈលើសពីការសហការធម្មតា
ដោយសារវាបង្កើតឱ្យមានភាពជាម្ចាស់រួមគ្នាលើការសម្រេចចិត្ត និងលទ្ធផលដែលទទួលបាន។

បេក្ខជនដែលមានសំណើគម្រោងរឹងមាំគួរតែអាចបង្ហាញឱ្យឃើញយ៉ាងច្បាស់ពីទំនាក់ទំនងរវាងការពង្រឹងភាពធន់ក្នុងការប្រឈមនឹងឧក្រិដ្ឋកម្មរៀបចំជាក្រុម កិច្ចសហការរវាងអង្គការ
និងការងារស្នូល ព្រមទាំងបេសកកម្មរបស់អង្គការខ្លួន។

ទីតាំងដែលមានសិទ្ធិអនុវត្តសកម្មភាព

សកម្មភាពគម្រោងត្រូវអនុវត្តនៅក្នុងតំបន់ និងទីតាំងមួយ ឬច្រើន ក្នុងប្រទេសមួយ ឬច្រើននៃបណ្តាប្រទេសមេគង្គ រួមមាន កម្ពុជា ឡាវ មីយ៉ាន់ម៉ា[1] ថៃ និង/ឬ វៀតណាម។ សកម្មភាពដែលបានស្នើឡើងអាចអនុវត្តនៅក្នុងប្រទេសណាមួយក្នុងចំណោមប្រទេសទាំងនេះ ឬនៅក្នុងប្រទេសច្រើនជាងមួយ។

លក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃ

សំណើគម្រោងរបស់អ្នកដាក់ពាក្យនឹងត្រូវបានវាយតម្លៃដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

១) លក្ខណៈវិនិច្ឆ័យពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង (២០%)

ក. **តួអង្គឧក្រិដ្ឋកម្ម (១០%)** –
កម្រិតដែលសំណើគម្រោងបង្ហាញភស្តុតាងអំពីប្រភេទនៃតួអង្គឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង ដែលកំពុងជះឥទ្ធិពលដល់សហគមន៍របស់អ្នកដាក់ពាក្យ។

ខ. **ទីផ្សារឧក្រិដ្ឋកម្ម (១០%)** – កម្រិតដែលសំណើគម្រោងបង្ហាញភស្តុតាងអំពីទំហំ និងវិសាលភាពនៃទីផ្សារឧក្រិដ្ឋកម្ម ដែលកំពុងជះឥទ្ធិពលដល់សហគមន៍។ **(១០%)**

២) **លក្ខណៈវិនិច្ឆ័យពាក់ព័ន្ធនឹងសហគមន៍(២០%)**

ក. **ការបញ្ជាក់អំពីអ្នកទទួលផល**–
កម្រិតដែលអ្នកដាក់ពាក្យផ្តល់នូវហេតុផលច្បាស់លាស់ក្នុងការជ្រើសរើសអ្នកទទួលផល ដែលរងផលប៉ះពាល់ពី ឬមានលទ្ធភាពជះឥទ្ធិពលលើប្រព័ន្ធអេកូឡូស៊ីនៃឧក្រិដ្ឋកម្ម **(៥%)**។

ខ. **ការបញ្ជាក់អំពីទីតាំងភូមិសាស្ត្រ**– កម្រិតដែលតំបន់ និងទីតាំងអនុវត្តសកម្មភាពមានភាពស៊ីសង្វាក់គ្នាជាមួយនឹងហេតុផលដែលបានផ្តល់អំពីឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង និងអ្នកទទួលផល**(៥%)**។

គ. **ការមានទំនាក់ទំនង និងការចាក់ឫសក្នុងសហគមន៍**– កម្រិតដែលអ្នកដាក់ពាក្យបង្ហាញថាខ្លួនមានទំនាក់ទំនងជិតស្និទ្ធ និងមានមូលដ្ឋានការងារនៅក្នុងសហគមន៍អ្នកទទួលផល (ដែលអាចផ្ទៀងផ្ទាត់បានតាមរយៈបុគ្គលដែលមានបទពិសោធន៍ផ្ទាល់ ទំនាក់ទំនង បណ្តាញ និងការភ្ជាប់ទំនាក់ទំនងផ្សេងៗ) ព្រមទាំងនៅក្នុងតំបន់ និងទីតាំងអនុវត្តសកម្មភាព (ដែលអាចផ្ទៀងផ្ទាត់បានតាមរយៈកម្មវិធី ឬគម្រោងដែលបានអនុវត្តកន្លងមក ឬកំពុងអនុវត្ត) **(១០%)** ។

៣) **លក្ខណៈវិនិច្ឆ័យពាក់ព័ន្ធនឹងភាពធន់ (៥០%)**

[1] Myanmar engagement will be reviewed on a case-by-case basis, should operating context allow.

ក. **វិធីសាស្ត្រពង្រឹងភាពធន់** –
កម្រិតដែលសកម្មភាពដែលអ្នកដាក់ពាក្យស្នើឡើងបញ្ចូលនូវវិធានការពង្រឹងភាពធន់
ដើម្បីទប់ទល់ សម្របខ្លួន និង/ឬ
កាត់បន្ថយសមត្ថភាពប្រតិបត្តិការរបស់ប្រព័ន្ធឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង**(១៥%)**។

ខ. **ការផ្តោតលើលទ្ធផល**– កម្រិតដែលទម្រង់
និងវិធីសាស្ត្រនៃសកម្មភាពដែលអ្នកដាក់ពាក្យស្នើឡើង
ទំនងជាអាចសម្រេចបាននូវលទ្ធផលដាក់ស្តែង**(១០%)**។

គ. **កិច្ចសហការ**–
កម្រិតដែលសកម្មភាពត្រូវបានអនុវត្តតាមរយៈកិច្ចសហការរវាងអង្គការដាក់ពាក្យ
និងតួអង្គនានានៅក្នុងសហគមន៍របស់ខ្លួន**(២៥%)** ។

៤) លក្ខណៈវិនិច្ឆ័យស្តីពីប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកា(១០%)

ក. **តម្លៃផ្ទៀបនឹងថវិកា**– កម្រិតដែលសំណើគម្រោងត្រូវបានរៀបចំ
និងអនុវត្តដោយប្រកាន់ខ្ជាប់នូវគោលការណ៍នៃការប្រើប្រាស់ថវិកាប្រកបដោយសន្សំសំចៃ
ប្រសិទ្ធភាព ការសម្រេចបានលទ្ធផល និងក្រមសីលធម៌**(៥%)** ។

ខ. **និរន្តរភាព** – កម្រិតដែលសកម្មភាពដែលបានស្នើឡើងបញ្ចូលនូវប្រព័ន្ធ
និងយន្តការនៅថ្នាក់សហគមន៍ ដើម្បីពង្រឹងភាពជាម្ចាស់ក្នុងមូលដ្ឋាន
និងសមត្ថភាពក្នុងមូលដ្ឋាន ដែលទំនងជានឹងបន្តមាន និងដំណើរការបាន
ទោះបីជាការផ្តល់មូលនិធិបានបញ្ចប់ក៏ដោយ**(៥%)** ។

របៀបដាក់ពាក្យស្នើសុំ

ដំណើរការដាក់ពាក្យស្នើសុំមានពីរដំណាក់កាល។ អ្នកដាក់ពាក្យដែលទទួលបានការវាយតម្លៃខ្ពស់
នឹងត្រូវបានអញ្ជើញឱ្យបន្តទៅដំណាក់កាលទីពីរ។

ដើម្បីដាក់ពាក្យស្នើសុំ អ្នកត្រូវ៖

១) **ដំណាក់កាលទីមួយ៖**

- បំពេញ**កម្រងសំណួរមុនពេលដាក់ពាក្យស្នើសុំ**

២) **ដំណាក់កាលទីពីរ៖**

- រៀបចំ និងដាក់**សំណើគម្រោងពេញលេញ** និង
- **ថវិកាដោយផ្អែកលើសកម្មភាព**

បន្ទាប់ពីការវាយតម្លៃលើពាក្យស្នើសុំនៅដំណាក់កាលទីពីររួច
អ្នកដាក់ពាក្យដែលទទួលបានពិន្ទុខ្ពស់ នឹងត្រូវបានអញ្ជើញឱ្យដាក់ឯកសារភ្ជាប់បន្ថែម
តាមការស្នើសុំជាក់លាក់ ដើម្បីឱ្យ GI-TOC អនុវត្តការត្រួតពិនិត្យ
និងការផ្ទៀងផ្ទាត់ឱ្យបានច្បាស់លាស់អំពីអ្នកដាក់ពាក្យ។
អ្នកដាក់ពាក្យមិនត្រូវដាក់ឯកសារភ្ជាប់បន្ថែមណាមួយឡើយ មុនពេលទទួលបានការអញ្ជើញពីGI-TOC។

អ្នកដាក់ពាក្យដែលទទួលបានពិន្ទុខ្ពស់ក្នុងការវាយតម្លៃដំណាក់កាលទីពីរ
នឹងត្រូវបញ្ជូនសំណើទៅកាន់គណៈកម្មាធិការផ្តល់ជំនួយរបស់ GI-TOC ដើម្បីពិនិត្យ
និងអនុម័តជាស្តាពរ។

សូមផ្ញើពាក្យស្នើសុំដំបូងទៅកាន់អាសយដ្ឋានអ៊ីម៉ែល <mnet-ctc-resilience@globalinitiative.net> ឱ្យបានមុន ឬត្រឹមថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៦ ម៉ោង ២៣:៥៩
(ម៉ោងនៅតំបន់ CEST)។

GI-TOC នឹងទទួលយកពាក្យស្នើសុំតែមួយប៉ុណ្ណោះពីអ្នកដាក់ពាក្យម្នាក់។
ប្រសិនបើអ្នកដាក់ពាក្យដាក់ពាក្យស្នើសុំច្រើនជាងមួយសម្រាប់សកម្មភាពគម្រោងដូចគ្នា GI-TOC
នឹងពិចារណាតែពាក្យស្នើសុំចុងក្រោយដែលបានដាក់ប៉ុណ្ណោះ។

កាលវិភាគនៃដំណើរការផ្តល់ជំនួយ

អ្នកដាក់ពាក្យត្រូវដាក់ពាក្យស្នើសុំក្នុងអំឡុងពេលចាប់ផ្តើម
នឹងបិទទទួលពាក្យដែលបានប្រកាសជាផ្លូវការ។ GI-TOC
នឹងមិនទទួលយកពាក្យស្នើសុំដែលដាក់យឺតជាងកាលកំណត់ឡើយ។

សកម្មភាព	រយៈពេល
រយៈពេលនៃឱកាសទទួលបានជំនួយ	១៥ ខែកុម្ភៈ ឆ្នាំ២០២៧ដល់១៥ ខែកុម្ភៈ ឆ្នាំ២០២៨
ការវាយតម្លៃលើពាក្យស្នើសុំដំបូង, អ្នកដាក់ពាក្យដែលទទួលបានពិន្ទុខ្ពស់ នឹងត្រូវបានអញ្ជើញឱ្យដាក់ពាក្យស្នើសុំពេញលេញ	៤សប្តាហ៍
ការវាយតម្លៃលើពាក្យស្នើសុំពេញលេញ, អ្នកដាក់ពាក្យដែលទទួលបានពិន្ទុខ្ពស់ នឹងត្រូវបានអញ្ជើញឱ្យដាក់ឯកសារភ្ជាប់បន្ថែម ហើយការអនុម័តចុងក្រោយនឹងធ្វើឡើងដោយគណៈកម្មាធិការផ្តល់ជំនួយ	៦សប្តាហ៍
កាលបរិច្ឆេទចាប់ផ្តើមសកម្មភាពគម្រោងដែលអាចចាប់ផ្តើមបានមុនគេ	១៥ ខែកុម្ភៈ ឆ្នាំ២០២៧
កាលបរិច្ឆេទបញ្ចប់សកម្មភាពគម្រោង ឬកិច្ចព្រមព្រៀងយឺតបំផុត	១៥ កុម្ភៈ ឆ្នាំ២០២៨
កាលបរិច្ឆេទបើក និងបិទទទួលពាក្យ	១ ខែវិច្ឆិកា ឆ្នាំ២០២៦ ដល់ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៦

សំណួរ ការសាកសួរ និងមតិយោបល់ក្នុងអំឡុងពេលដាក់ពាក្យស្នើសុំ

ប្រសិនបើអ្នកដាក់ពាក្យមានសំណួរ ចង់សាកសួរ
ឬមានមតិយោបល់ពាក់ព័ន្ធនឹងពាក្យស្នើសុំរបស់ខ្លួន ឬដំណើរការដាក់ពាក្យស្នើសុំ
សូមទាក់ទងតាមអាសយដ្ឋានអ៊ីម៉ែល៖ <mnet-ctc-resilience@globalinitiative.net>

អ្នកដាក់ពាក្យអាចស្នើសុំព័ត៌មានលម្អិតបន្ថែម ឬការបញ្ជាក់ឱ្យកាន់តែច្បាស់អំពីដំណើរការនេះ
ដោយផ្ញើអ៊ីម៉ែលទៅកាន់អាសយដ្ឋានខាងលើ។

លក្ខខណ្ឌតម្រូវអំពីភាសា

ឯកសារដាក់ពាក្យស្នើសុំទាំងអស់ រួមមានកម្រងសំណួរមុនពេលដាក់ពាក្យស្នើសុំ
សំណើគម្រោងពេញលេញ ថវិកាដោយផ្អែកលើសកម្មភាព និងឯកសារភ្ជាប់បន្ថែមទាំងអស់
អាចដាក់ជាភាសាអង់គ្លេស ឬជាភាសាសំខាន់មួយក្នុងចំណោមភាសានៃបណ្តាប្រទេសមេគង្គ
រួមមាន ភាសាខ្មែរ ឡាវ ថៃ ឬវៀតណាម។

ឯកសារដាក់ពាក្យស្នើសុំជាភាសាទាំងនេះ អាចរកបានតាមរយៈ
https://globalinitiative.net/announcements/calling-innovative-proposals-to-combat-organized-crime-in-the-mekong/ ។

ដំណើរការជ្រើសរើសគម្រោងទទួលជំនួយ

អ្នកណាជាអ្នកវាយតម្លៃពាក្យស្នើសុំ?

គណៈកម្មាធិការវាយតម្លៃនឹងពិនិត្យ និងវាយតម្លៃពាក្យស្នើសុំនីមួយៗ ដោយផ្អែកលើគុណសម្បត្តិ
និងខ្លឹមសាររបស់សំណើនីមួយៗ។ គណៈកម្មាធិការវាយតម្លៃនេះមានសមាសភាពជាបុគ្គលិករបស់
GI-TOC ដែលបំពេញតួនាទីផ្សេងៗគ្នាក្នុងការអនុវត្តកម្មវិធី និងការងារមុខងារគាំទ្រផ្សេងៗ។
គណៈកម្មាធិការវាយតម្លៃនឹងពិនិត្យសំណើគម្រោង និងថវិកានីមួយៗ
ព្រមទាំងផ្តល់ពិន្ទុដោយផ្អែកលើលក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃ។

គណៈកម្មាធិការវាយតម្លៃនឹងដាក់ជូនក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី (DFAT)
នូវសេចក្តីសង្ខេបអំពីសំណើគម្រោងរបស់អ្នកដាក់ពាក្យ
ដែលគណៈកម្មាធិការស្នើឱ្យមានការអនុម័ត។ បន្ទាប់ពីទទួលបានការយល់ព្រមពី DFAT
ពាក្យស្នើសុំទាំងនោះនឹងត្រូវបញ្ជូនទៅគណៈកម្មាធិការផ្តល់ជំនួយរបស់ GI-TOC ដើម្បីពិនិត្យ
និងអនុម័តជាស្ថាពរ។

គណៈកម្មាធិការផ្តល់ជំនួយនេះមានសមាសភាពជាថ្នាក់ដឹកនាំជាន់ខ្ពស់របស់ GI-TOCនៅកម្រិតសកល ដែលទទួលខុសត្រូវលើការកំណត់ទិសដៅ និងការគ្រប់គ្រងកម្មវិធីជារួម។
គណៈកម្មាធិការផ្តល់ជំនួយរបស់ GI-TOC នឹងចេញសេចក្តីសម្រេចចុងក្រោយ។

អ្នកណាជាអ្នកអនុម័តការផ្តល់ជំនួយ?

គណៈកម្មាធិការផ្តល់ជំនួយរបស់ GI-TOC
ជាអ្នកសម្រេចថាតើគម្រោងណាខ្លះនឹងទទួលបានការអនុម័ត
ដោយពិចារណាលើអនុសាសន៍របស់គណៈកម្មាធិការវាយតម្លៃ មតិយោបល់របស់ម្ចាស់ជំនួយ

(រដ្ឋាភិបាលអូស្ត្រាលី) និងលទ្ធភាពនៃមូលនិធិជំនួយដែលមានសម្រាប់កម្មវិធីនេះ។
គណៈកម្មាធិការអាចស្នើឱ្យអ្នកដាក់ពាក្យកែសម្រួល
ឬធ្វើបច្ចុប្បន្នភាពឯកសារដាក់ពាក្យស្នើសុំដែលបានដាក់ជូន។

សេចក្តីសម្រេចរបស់គណៈកម្មាធិការគ្រប់គ្រងជំនួយរបស់ GI-TOC
គឺជាសេចក្តីសម្រេចចុងក្រោយលើគ្រប់បញ្ហា រួមមាន៖

- ការអនុម័តផ្តល់ជំនួយ និង
- ចំនួនទឹកប្រាក់ជំនួយដែលត្រូវផ្តល់ជូន។

មិនមានយន្តការប្តឹងតវ៉ាចំពោះសេចក្តីសម្រេចអនុម័ត ឬមិនអនុម័តការផ្តល់ជំនួយឡើយ។

គណៈកម្មាធិការផ្តល់ជំនួយរបស់ GI-TOC នឹងមិនអនុម័តការផ្តល់មូលនិធិឡើយ
ប្រសិនបើគណៈកម្មាធិការយល់ឃើញដោយមានហេតុផលសមស្របថា
មូលនិធិរបស់កម្មវិធីដែលមានស្រាប់មិនអាចផ្គត់ផ្គង់ដល់ការផ្តល់ជំនួយដែលបានស្នើឡើងបាន
និង/ឬ សំណើគម្រោងមិនបង្ហាញពីតម្លៃសមស្របធៀបនឹងថវិកាដែលបានស្នើសុំ។ GI-TOC
រក្សាសិទ្ធិក្នុងការផ្តល់ទឹកប្រាក់ជំនួយតិចជាងចំនួនដែលអ្នកដាក់ពាក្យបានស្នើសុំ។

ការជូនដំណឹងអំពីលទ្ធផលនៃការដាក់ពាក្យស្នើសុំ

GI-TOC នឹងជូនដំណឹងដល់អ្នកដាក់ពាក្យអំពីលទ្ធផលនៃការដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរ។
ប្រសិនបើពាក្យស្នើសុំទទួលបានជោគជ័យ GI-TOC
នឹងជូនដំណឹងដល់អ្នកដាក់ពាក្យអំពីលក្ខខណ្ឌជាក់លាក់ណាមួយដែលភ្ជាប់ជាមួយការផ្តល់ជំនួយ។

ការដាក់ពាក្យស្នើសុំមិនទទួលបានជោគជ័យ
មិនមែនជាឧបសគ្គរារាំងអ្នកដាក់ពាក្យពីការដាក់ពាក្យស្នើសុំក្នុងឱកាសទទួលបានមូលនិធិនាពេលអនាគតឡើយ៕